# កំរងសំនួរចំលើយដែលមានសួរជាញឹកញាប់
# ទាក់ទងនឹងសុវត្ថិភាព និងសន្តិសុខនៅមណ្ឌលអប់រំឡុងប៊ីច LBUSD

ជារៀងរាល់ថ្ងៃ សាលារៀនយើងខ្ញុំធ្វើការយ៉ាងស្និទ្ធស្នាលជាមួយនឹងអាជ្ញាធរអនុវត្តច្បាប់ ដោយភាគច្រើនគឺធ្វើការពីក្រោយឆាក ក្រោមគោលបំណងដើម្បីរក្សាសុវត្ថិភាពដល់សិស្សានុសិស្សរបស់យើង។ ដោយហេតុផលរក្សាសុវត្ថិភាព យើងខ្ញុំបដិសេធសូមមិនចែករំលែកនូវព័ត៌មានលំអិត ទាក់ទងនឹងពិធីការវិធីសាស្ត្រនានា ដែលការិយាល័យសុវត្ថិភាពសាលានិងការត្រៀមលក្ខណៈសំរាប់សង្គ្រោះបន្ទាន់ (Office of School Safety and Emergency Preparedness) របស់យើងខ្ញុំបានបង្កើតឡើងជាមួយខាងអាជ្ញាធរអនុវត្តច្បាប់។ ក៏ប៉ុន្តែ កំរងសំនួរចំលើយដែលមានសួរជាញឹកញាប់ គឺបានរៀបរាប់អំពីក្របខ័ណ្ឌសុវត្ថិភាពនិងកិច្ចប្រុងប្រយ័ត្នសំខាន់ៗរបស់យើងខ្ញុំ។ ជានិច្ចកាល យើងខ្ញុំបន្តកែប្រែនិងកែលំអទៅលើផែនការសុវត្ថិភាពរបស់យើងខ្ញុំ ក្រោមសេចក្តីណែនាំរបស់ស្ថាប័ននិងអ្នកជំនាញខាងអជ្ញាធរអនុវត្តសុវត្ថិភាពទាំងនៅក្នុងតំបន់និងថ្នាក់ជាតិ។

## កំរងសំនួរចំលើយដែលមានសួរជាញឹកញាប់

**តើសាលារៀនមានចាត់វិធានការអ្វីខ្លះ ដើម្បីឆ្លើយតបនឹងជនឈ្លានពាន ឬជនបាញ់សកម្ម?**

ច្បាប់រដ្ឋតំរូវឲ្យគ្រប់សាលារៀនរក្សាទុក និងធ្វើបច្ចុប្បន្នភាពលើ «ផែនការសុវត្ថិភាពសាលាគ្រប់ជ្រុងជ្រោយ» ដែលរួមមានផែនការប្រតិបត្តិការគ្រោះអាសន្ន សំរាប់គ្រោះអាសន្នដែលអាចកើតឡើងបាន ព្រមទាំងផែនការសាលាមានសុវត្ថិភាព ដើម្បីលើកកំពស់បរិយាកាសសាលារៀនដែលប្រកបដោយសុវត្ថិភាពនិងសន្តិសុខ។ នៅតាមសាលារៀននីមួយៗនៃមណ្ឌល LBUSD គឺមានដាក់ប្រើប្រាស់នៅនឹងកន្លែង នូវស្តង់ដារនីតិវិធីសង្គ្រោះបន្ទាន់ និងវិធានការសន្តិសុខ និងការការពារ។ ការហ្វឹកសមសមមួយចំនួនត្រូវបានបញ្ជារដោយរដ្ឋាភិបាលសហព័ន្ធ ហើយខ្លះទៀតត្រូវបានបញ្ជារដោយការិយាល័យសុវត្ថិភាពសាលានិងការត្រៀមលក្ខណៈសំរាប់សង្គ្រោះបន្ទាន់។ លើសពីនេះទៅទៀត សាលារៀននីមួយៗមានបំពាក់នូវប្រព័ន្ធស្វ័យប្រវត្តិមួយ ដែលអនុញ្ញាតឲ្យបុគ្គលិកសាលាធ្វើការទាក់ទងទៅរាល់គ្រូបង្រៀននិងសិស្សានុសិស្សគ្រប់ៗគ្នាក្នុងករណីមានអាសន្ននៅក្នុងបរិវេណសាលារៀន។ ជាទៀងទាត់ គ្រូៗនិងបុគ្គលិក គឺពិនិត្យមើលផែនការសុវត្ថិភាពនិងសេចក្តីណែនាំជាមួយសិស្សានុសិស្ស និងធ្វើការហ្វឹកសមសង្គ្រោះបន្ទាន់។ ផែនការសុវត្ថិភាពត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ហើយអ្នកអាចរកមើលច្បាប់ចំលងឯកសារនេះ នៅតាមសាលានីមួយៗបាន។

«ផែនការសុវត្ថិភាពសាលាគ្រប់ជ្រុងជ្រោយ» រួមមាន៖

- លំហាត់សមក្នុងករណីមានជនបាញ់សកម្ម
- ផែនការនានាសំរាប់ករណីផ្សេងៗ៖ រញ្ជួយផែនដី ជនឈ្លានពាន ជនបាញ់សកម្ម ករណីបិទច្រកទ្វារមិនមិនឲ្យចេញពីសាលាបាន ករណីបិទច្រកទ្វារមិនឲ្យចូលសាលាបាន។ល។
- ការត្រៀមលក្ខណៈសំរាប់គ្រោះមហន្តរាយ
- ការថែរក្សាបរិស្ថានសាលារៀនឲ្យមានសុវត្ថិភាព។

**តើមណ្ឌលអប់រំបានធ្វើអ្វីខ្លះ ដើម្បីគ្រប់គ្រងអ្នកធ្វើទស្សនកិច្ចសាលា ឬអ្នកខាងក្រៅចូលមកប្រើប្រាស់សាលារៀន? តើមណ្ឌលអប់រំបានធ្វើការកែលំអសន្តិសុខសាលារៀនបានយ៉ាងដូចម្តេចខ្លះ?**

សាលារៀននៅក្រោមមណ្ឌលអប់រំ គឺចាត់ទុកជា «សាលាបរិវេណបិទជិត»។ នេះមានន័យថាខាងមណ្ឌលអប់រំបានបញ្ជាក់ថា គ្រប់សាលារៀនទាំងអស់ មានតែចំណុចចូល/កន្លែងចុះឈ្មោះតែមួយគត់សំរាប់ភ្ញៀវទាំងឡាយ។

នៅពេលបច្ចុប្បន្ននេះ ច្បាប់រដ្ឋនិងគោលការណ៍ក្រុមប្រឹក្សាភិបាល តំរូវឲ្យភ្ញៀវបង្ហាញអត្តសញ្ញាណប័ណ្ណរបស់ពួកគេ ដើម្បីផ្ទៀងផ្ទាត់ថាពួកគេជានរណា ហើយមានមូលហេតុអ្វីក្នុងការស្នើសុំទស្សនកិច្ចនេះ។

កាលពីឆ្នាំ 2018 មណ្ឌលអប់រំ LBUSD បានបែងចែកថវិកាចំនួន 11លានដុល្លារ សំរាប់ដាក់នូវប្រដាប់សុវត្ថិភាពនិងសន្តិសុខបន្ថែមឲ្យមាននៅតាមសាលារៀនក្នុងតំបន់។ ការវិនិយោគទុនទៅលើសុវត្ថិភាពសាលារៀននេះ រួមមានធ្វើរបងព័ទ្ធជុំវិញបរិវេណសាលាបន្ថែមទៀត ដើម្បីបង្កើតជាបរិវេណបិទជិត នៅតាមសាលារៀនជាច្រើនទូទាំងមណ្ឌលអប់រំ LBUSD ទាំងមូល។ កាមេរ៉ាសុវត្ថិភាព និងទ្វារចូលមានកណ្តឹងសុវត្ថិភាពក៏ត្រូវបានគេដាក់បន្ថែមនៅតាមច្រកចូលសំខាន់ៗនៅគ្រប់សាខាសាលារៀនទាំងអស់។ ការបន្ថែមប្រដាប់សុវត្ថិភាពទាំងនេះមានន័យថា សាធារណៈជនគឺមិនអាចចូលទៅក្នុងបរិវេណសាលាបានទេ នៅក្រោយម៉ោងធ្វើការនិងនៅចុងសប្តាហ៍ លើកលែងតែមានការអនុញ្ញាតពិសេសពីមណ្ឌលអប់រំសាលា។ ភ្ញៀវទាំងឡាយ គួរចងចាំពីវិធានការសុវត្ថិភាពបន្ថែមទាំងនេះ ដោយមានដាក់ការណាត់ជួបជាមុនបើសិនជាអាចធ្វើបាន ព្រមទាំងប្រើច្រកចូលសំខាន់ឬខាងមុខ នៅពេលមកដល់បរិវេណសាលារៀន។

មុននិងក្រោយពេលចូលរៀន ចំនួនច្រកទ្វារចូលដែលមានបើក គឺមានកំណត់ ហើយបុគ្គលិកយើងខ្ញុំតែងតែធ្វើការត្រួតពិនិត្យនៅគ្រប់ច្រកទ្វារដែលបើក។ ច្រកទ្វារមិនសំខាន់ត្រូវបានបិទហើយចាក់សោរជាប់ បន្ទាប់ពីសិស្សចូលរៀននិងចេញពីរៀន។ បន្ទាប់ពីម៉ោងរៀនត្រូវបានចាប់ផ្តើម គ្រប់ភ្ញៀវខាងក្រៅទាំងឡាយ គឺត្រូវតែធ្វើការចុះឈ្មោះនៅការិយាល័យសាលា ដើម្បីស្នើសុំការអនុញ្ញាតចូលទៅក្នុងបរិវេណសាលារៀន ដោយមានហេតុផលជាក់លាក់។ គ្រប់ភ្ញៀវខាងក្រៅទាំងឡាយ គឺត្រូវតែចុះឈ្មោះ និងផ្តល់ជាហេតុផលត្រឹមត្រូវដើម្បីចូលទស្សនាក្នុងសាលា។

សាលារៀនយើងខ្ញុំ ស្វាគមន៍ការចូលរួមរបស់មាតាបិតានិងសហគមន៍ ហើយជារឿយៗ សាលារៀនគឺជាមជ្ឈមណ្ឌលជួបជុំសំរាប់សហគមន៍នៅជុំវិញ។ ទោះជាយ៉ាងណាក៏ដោយ គោលបំណងទីមួយរបស់សាលារៀន គឺផ្តល់ការអប់រំដល់សិស្សានុសិស្ស។ នៅក្រោមច្បាប់ គឺសាលារៀនមិនត្រូវបានចាត់ទុកថា បើកចំហចំពោះសាធារណៈជន ឬជាវេទិកាសាធារណៈដូចជា សួនច្បារឬចិញ្ចើមផ្លូវសាធារណៈនោះទេ។ ផ្ទុយទៅវិញ សាលារៀនត្រូវបានចាត់ទុកថាជា «វេទិកាសាធារណៈមានកំណត់» ហើយអាចដាក់កំណត់ការចូលប្រើប្រាស់ជាសាធារណៈ ដោយអនុលោមតាមបទបញ្ញត្តិសមហេតុផលរបស់សាលា។

ច្បាប់រដ្ឋទាមទារឲ្យមានការចុះឈ្មោះនិងការបង្ហាញវត្តមាន ដើម្បីសុំការអនុញ្ញាតចូលទស្សនាក្នុងបរិវេណសាលារៀន។ គោលបំណងរបស់បទបញ្ញត្តិនេះ គឺ៖

- កាត់បន្ថយការរំខានដល់ដំណើរការអប់រំរបស់សាលា
- កំរិតការចូលប្រើប្រាស់សាលា សំរាប់អ្នកដែលគ្មានកិច្ចការអ្វីទាក់ទងនឹងត្រូវឲ្យចូលមកក្នុងបរិវេណសាលារៀន ដែលពួកគាត់អាចរំខានដល់ដំណើរការអប់រំរបស់សាលា ឬបង្កការគំរាមកំហែងដល់សិស្សានុសិស្ស និងបុគ្គលិកសាលា
- ដឹងថាអ្នកណាខ្លះកំពុងនៅក្នុងបរិវេណសាលា និងពីអ្នកចូលនិងចេញពីក្នុងបរិវេណសាលា
- ក្នុងករណីមានអាសន្ន យើងអាចទទួលខុសត្រូវលើបុគ្គលគ្រប់ៗគ្នានៅក្នុងបរិវេណសាលា

**តើមណ្ឌលអប់រំ LBUSD មានគោលការណ៍ ច្បាប់វិន័យ ឬការរំពឹងទុកអ្វីខ្លះ សំរាប់ភ្ញៀវឬអ្នកខាងក្រៅដែលមកទស្សនាធ្វើកិច្ចការលើបរិវេណសាលារៀនឬបរិវេណមណ្ឌលអប់រំ?**

យោងតាមការណែនាំរបស់ «ក្រមរដ្ឋប្បវេណីនិងក្រមការអប់រំរដ្ឋកាលីហ្វ័រញ៉ា» (California Civil Code and Education Code) និងដូចមានចែងក្នុង «គោលការណ៍ប្រចាំឆ្នាំរបស់មណ្ឌលអប់រំ LBUSD សំរាប់មាតាបិតានិងសិស្សានុសិស្ស»៖

មណ្ឌលអប់រំរំពឹងថា បុគ្គលទាំងអស់ដែលចូលរួមក្នុងកិច្ចការសកម្មភាពសាលា ត្រូវរក្សាភាពស៊ីវីល័យ។ ការគោរពគ្នាទៅវិញទៅមក វិជ្ជាជីវៈ និងសុជីវធម៌ទូទៅ គឺជាគុណសម្បត្តិសំខាន់ៗក្នុងការលើកកំពស់បរិយាកាសនៃការអប់រំនិងការងារមួយ ដែលជៀសឆ្ងាយពីការរំខាន ការយាយីការគំរាមកំហែង និងការប្រើប្រាស់កំហឹង។ ជនណាដែលបង្កការរំខានដោយចេតនាដល់សាលារដ្ឋឬកិច្ចប្រជុំសាលារដ្ឋណាមួយ គឺមានទោសបទមជ្ឈឹម ហើយត្រូវពិន័យជាទឹកប្រាក់ដល់ទៅ 500ដុល្លារ។ ការមានចេតនា ឬប៉ុនប៉ងបង្កជារបួសស្នាម បំភិតបំភ័យ ជ្រៀតជ្រែកដោយប្រើ

កម្លាំង ការគំរាមកំហែងដោយប្រើប្រាស់កម្លាំង ការរារាំងដោយប្រើហិង្សា ឬការរារាំងដោយមិនប្រើប្រាស់ហិង្សា លើបុគ្គលណាក៏ដោយមានគោលបំណងចូលមកឬចាកចេញពីក្នុងបរិវេណសាលារៀនទាំងសាធារណៈនិងឯកជន គឺសុទ្ធសឹងតែខុសច្បាប់ទាំងអស់។

**តើមណ្ឌលអប់រំមានវិធីសាស្រ្តអ្វីខ្លះក្នុងការកំណត់អត្តសញ្ញាណបុគ្គលណា ដែលមានតំរុយបង្កការគំរាមកំហែងការប៉ុនប៉ងអំពើហិង្សាក្នុងសាលារៀន មុនពេលមានអំពើហិង្សាកើតឡើង?**

ក្រោមការសហការជាដៃគូជាមួយនឹង ការិយាល័យសុវត្ថិភាពសាលានិងការត្រៀមលក្ខណៈសំរាប់សង្គ្រោះបន្ទាន់ និង អជ្ញាធរអនុវត្តច្បាប់ក្នុងតំបន់ គឺមណ្ឌល LBUSD បានដាក់អោយមានការអនុវត្តនូវ «ពិធីការវាយតម្លៃការគំរាមកំហែង» សំរាប់វាយតម្លៃលើភ្ញៀវ សិស្សានុសិស្ស និង/ឬបុគ្គលិក ដែលត្រូវបានគេកំណត់អត្តសញ្ញាណថា អាចនឹងមានសក្តានុពលក្នុងការបង្កការគំរាមកំហែងប៉ុនប៉ងអំពីអំពើហិង្សាក្នុងសាលា ឬនឹងការធ្វើបាបដល់ខ្លួនឯង។ ការវាយតម្លៃលើការគំរាមកំហែងនេះ អាចនឹងត្រូវធ្វើឡើងបើសិនជាមានការជំរុញដោយពាក្យសំដី អាកប្បកិរិយា ការឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរ email ផ្ញើសារតាមទូរសព្ទជាដើម របស់បុគ្គលណាម្នាក់។

**តើសាលាមានត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់សិស្ស ក៏ដូចជាកំព្យូទ័រដែលមណ្ឌលអប់រំជាអ្នកចេញឲ្យប្រើ ដើម្បីរកមើលការគំរាមកំហែងប៉ុនប៉ងធ្វើអំពើហិង្សាក្នុងសាលារៀន ឬការធ្វើបាបខ្លួនឯងដែរឬទេ?**

មាន។ កម្មវិធី software ដែលដាក់នៅលើកំព្យូទ័រចែកចាយឲ្យសិស្សានុសិស្សនៅមណ្ឌលអប់រំ LBUSD គឺត្រូវបានគេត្រងទិន្នន័យដោយស្វ័យប្រវត្តិ ហើយ software នេះ នឹងជូនដំណឹងដល់បុគ្គលិកសាលា បើសិនជាមានរកឃើញនូវការគំរាមកំហែងអំពើហិង្សា ឬការធ្វើបាបខ្លួនឯង។ ការត្រងទិន្នន័យមានគោលបំណង ដើម្បីទប់ស្កាត់សិស្សកុំឲ្យចូលទៅកាន់គេហទំព័រដែលមិនល្អនិងមិនអាចទទួលយកបាន និងដើម្បីជូនដំណឹងដល់បុគ្គលិកសាលាអំពីសិស្សដែលប្រឈមនឹងហានិភ័យក្នុងការធ្វើបាបខ្លួនឯង អំពើហិង្សាក្នុងសាលារៀន ឬការធ្វើអត្តឃាត។ មណ្ឌលអប់រំធ្វើការវាយតម្លៃនិងរារាំងសំណើចូលប្រើគេហទំព័ររាប់លានក្នុងមួយថ្ងៃៗ ហើយមានលទ្ធភាពក្នុងការជូនដំណឹងដោយស្វ័យប្រវត្តិដល់បុគ្គលិកមណ្ឌលអប់រំ បើសិនជាមានគេស្វែងរកពាក្យក្រោមប្រភេទមួយចំនួន (ដូចជា៖ អំពើអត្តឃាត កាំភ្លើង ការស្អប់ខ្ពើម អំពើភេរវកម្ម)។

ការិយាល័យសុវត្ថិភាពសាលារៀននិងការត្រៀមលក្ខណៈសង្គ្រោះបន្ទាន់ រួមជាមួយនឹងអជ្ញាធរអនុវត្តច្បាប់ក្នុងតំបន់ ព្រមទាំងការិយាល័យសេវាកម្មទីផ្សារនិងប្រព័ន្ធផ្សព្វផ្សាយរបស់មណ្ឌលអប់រំ LBUSD ធ្វើការតាមដានយ៉ាងសកម្មទៅលើប្រព័ន្ធផ្សព្វផ្សាយ ដើម្បីរកមើលការគំរាមកំហែងប៉ុនប៉ងណាមួយ ឬខ្លឹមសារមិនសមរម្យ រួមមានការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិ ដើម្បីចាប់អាកប្បកិរិយាដែលអាចបង្កគ្រោះថ្នាក់។

នៅពេលមានការជូនដំណឹងនីមួយៗ សាលាឆ្លើយតបវិញជាមួយនឹងការវាយតម្លៃការគំរាមកំហែង ឬវាយតម្លៃអំពើអត្តឃាត ដើម្បីធានាថាសិស្សអាចទទួលបានជំនួយនិងសេវាកម្មតាមតំរូវការ។ ការត្រងព័ត៌មាននេះ មានសកម្មភាព 24ម៉ោង 7ថ្ងៃពេញតែម្តង ហើយមាតាបិតាសិស្សនឹងត្រូវបានគេជូនដំណឹងផ្ទាល់ នៅពេលដែលប្រព័ន្ធចាប់ទិន្នន័យនេះ បានជូនដំណឹងដល់បុគ្គលិកសាលា ថាកូនរបស់ពួកគាត់ត្រូវបានគេកំណត់អត្តសញ្ញាណថា អាចនឹងធ្វើបាបខ្លួនឯង ឬបង្កអំពើហិង្សាក្នុងសាលា។

លើសពីនេះទៅទៀត ចំលើយរបស់សិស្សនៅលើក្រដាសប្រឡងប្រចាំរដ្ឋ ត្រូវបានគេត្រួតពិនិត្យនៅថ្នាក់រដ្ឋដើម្បីរកមើលភាសាឬពាក្យដែលចង្អុលបង្ហាញថា សិស្សនោះត្រូវការជំនួយដើម្បីទប់ស្កាត់កុំអោយធ្វើបាបខ្លួនឯងនិងអ្នកដទៃ។ នៅពេលកម្មវិធីប្រឡងផ្តល់ព័ត៌មានមកខាងសាលាភ្លាម ខាងមណ្ឌលអប់រំ ក៏ដូចជាសាលារៀននឹងទាក់ទងទៅកាន់សិស្សរូបនោះដើម្បីតាមដាន និងផ្តល់ជាជំនួយ។

ព័ត៌មានទាក់ទងនឹងវិធីសិស្សប្រើប្រាស់បច្ចេកវិទ្យារបស់មណ្ឌលអប់រំ LBUSD គឺមានចែងក្នុង «គោលការណ៍មណ្ឌលអប់រំ LBUSD សំរាប់មាតាបិតានិងសិស្សានុសិស្ស»។

**តើអាជ្ញាធរអនុវត្តច្បាប់មានតួនាទីអ្វីខ្លះ ក្នុងការត្រួតពិនិត្យមើលការគំរាមកំហែងប៉ុនប៉ងអំពើហិង្សាក្នុងសាលារៀន?**

ភ្នាក់ងារផ្សេងៗ ដូចជានាយកដ្ឋានប៉ូលីសនៅទីក្រុងឡុងប៊ីច និងស្នងការប៉ូលីសក្រុង Los Angeles ធ្វើការជាមួយការិយាល័យសុវត្ថិភាព

សាលានិងការត្រៀមលក្ខណៈសំរាប់សង្គ្រោះបន្ទាន់របស់សាលា LBUSD ដើម្បីធ្វើការត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយសង្គម ចរាចរណ៍លើគេហទំព័រ និង email ហើយធ្វើការឆ្លើយតបចំពោះការគំរាមគំហែងដែលបានរកឃើញដោយអាជ្ញាធរអនុវត្តច្បាប់ ឬដោយមណ្ឌល LBUSD ផ្ទាល់។ អាជ្ញាធរអនុវត្តច្បាប់នឹងផ្តល់ព័ត៌មានទៅអោយ LBUSD ប្រសិនបើគេរកឃើញពីគំរុយនៃការគំរាមកំហែងដែលអាចកើតឡើងមកលើសិស្សានុសិស្សនៅក្នុងមណ្ឌលអប់រំ ឬក្នុងសាលារៀន។

**តើបុគ្គលិកសាលានិងសិស្សបានទទួលការហ្វឹកហាត់អំពីនីតិវិធីក្នុងករណីមានជនឈ្លានពាន ឬជនបាញ់សកម្មដែរឬទេ?**

មាន។ គ្រប់បរិវេណសាលារៀនទាំងអស់ គឺទទួលបានការហ្វឹកហាត់ជារៀងរាល់ឆ្នាំ ដើម្បីត្រៀមលក្ខណៈក្នុងការប្រឈមជាមួយនឹងជនបាញ់សកម្ម ឬជនឈ្លានពានប្រដាប់ដោយអាវុធ។ នីតិវិធីសំរាប់ទប់ទល់នឹងការគំរាមកំហែងទាំងនេះរួមនៅក្នុង «ផែនការសុវត្ថិភាពសាលាគ្រប់ជ្រុងជ្រោយ»។ បុគ្គលិកនៅក្នុងបរិវេណសាលា ក៏ទទួលបានការហ្វឹកហាត់ដើម្បីយល់ពីការប្រើប្រាស់ប្រព័ន្ធបិទច្រកទ្វារមិនឲ្យចេញពីសាលាបានដោយស្វ័យប្រវត្តិនៅតាមសាលារៀននីមួយៗ។

**តើគេអាចសំគាល់បានថា អ្នកធ្វើទស្សនកិច្ចនិងសមាជិកបុគ្គលិកសាលា គឺខុសគ្នាដោយរបៀបណា?**

បុគ្គលិករបស់មណ្ឌលអប់រំត្រូវតែពាក់ប័ណ្ណសំគាល់ជាប់ខ្លួនជានិច្ច  ហើយអ្នកចូលទៅទស្សនាឬអ្នកខាងក្រៅនឹងទទួលបានប័ណ្ណឆ្លងកាត់/ប័ណ្ណពាក់ចូលសាលា សំរាប់ទស្សនកិច្ចបន្ទាប់ពីចុះឈ្មោះរួចរាល់។

**តើការគំរាមកំហែងប៉ុនប៉ងអំពើហិង្សាក្នុងសាលា ការសំលុតឃាយី ការបំផ្លិចបំផ្លាញ ការវាយសម្រុកចូល ឬកង្វល់ផ្សេងៗ អាចត្រូវបានគេរាយការណ៍ជាអនាមិកដែរឬទេ?**

គ្រួសារសិស្ស សិស្ស និងបុគ្គលិកអាចរាយការណ៍អំពីករណីឧប្បត្តិហេតុឬកង្វល់ផ្សេងៗ ទៅកាន់អាជ្ញាធរអនុវត្តច្បាប់ក្នុងតំបន់ ឬក៏ «មជ្ឍមណ្ឌលទាក់ទង24ម៉ោង 7ថ្ងៃ» របស់ការិយាល័យសុវត្ថិភាពសាលានិងការត្រៀមលក្ខណៈសំរាប់សង្គ្រោះបន្ទាន់។ ប្រសិនបើមានការស្នើសុំ ការរាយការណ៍នោះនឹងត្រូវបានគេរក្សាជាអនាមិក។

លេខទូរស័ព្ទសំខាន់ៗសំរាប់ធ្វើការទាក់ទង៖

នាយកដ្ឋានប៉ូលីសនៅទីក្រុង Long Beach

- អាសន្នគ្រប់បែបយ៉ាងទាំងអស់៖ 911
- ប៉ូលីស Long Beach - ខ្សែសំរាប់មិនសង្គ្រោះបន្ទាន់៖ 562-435-6711
- បញ្ជីលេខទូរស័ព្ទរបស់នាយកដ្ឋានប៉ូលីស Long Beach

ការិយាល័យសុវត្ថិភាពសាលានិងការត្រៀមលក្ខណៈសំរាប់សង្គ្រោះបន្ទាន់

- ខ្សែសំរាប់សង្គ្រោះបន្ទាន់នៅសាលា ឬសុវត្ថិភាពសាលា៖ 562-997-8101
- ខ្សែសំរាប់មិនសង្គ្រោះបន្ទាន់ ឬសុវត្ថិភាពក្នុងសាលា៖ 562-997-8006
- មណ្ឌលទាក់ទង24ម៉ោង 7ថ្ងៃ សំរាប់សុវត្ថិភាពសាលា៖ 562-997-8101
- ការិយាល័យរដ្ឋបាលសុវត្ថិភាពសាលា៖ 562-997-8006
- ខ្សែសំរាប់មិនសង្គ្រោះបន្ទាន់ - ការត្រៀមលក្ខណៈសំរាប់សង្គ្រោះបន្ទាន់៖ 562-997-8338

LONG BEACH UNIFIED SCHOOL DISTRICT
Excellence & Equity

**តើយើងរឹតបន្តឹងសុវត្ថិភាពនៅតាមសាលានានាដែរឬទេ នៅពេលបានឮដំណឹងពីការបាញ់កាំភ្លើងនៅតាមកសាលាកន្លែងដទៃទៀត?**

ស្របពេលដែលមណ្ឌលអប់រំ LBUSD តែងតែមានធ្វើបច្ចុប្បន្នភាពនិងកែតម្រូវនូវពិធីការនិងការណែនាំ ទាក់ទងទៅនឹងសុវត្ថិភាពនិងសន្តិសុខក្នុងសាលា យើងខ្ញុំក៏បានត្រួតពិនិត្យបន្ថែមទៅលើស្ថានការណ៍ផ្សេងៗ ដូចជាការបាញ់កាំភ្លើងនៅតាមសាលាកន្លែងដទៃទៀត ដើម្បីធ្វើការកំណត់សំគាល់ថា តើយើងត្រូវធ្វើការផ្លាស់ប្តូរបន្ថែមទៅលើនីតិវិធីដែលមានចែងស្រាប់ដែរឬទេ។ យើងប្រើប្រាស់ការណែនាំដែលរួមមានខាងក្រោម នៅក្នុងការពិនិត្យ និងឆ្លើយតប៖

- កំណត់បង្ហាញពីតំរូវការសុវត្ថិភាពបន្ថែម និងប្រសិនបើចាំបាច់ ធ្វើការសំរបសំរួលអោយមានកិច្ចប្រឹងប្រែងសហការជាមួយភ្នាក់ងារអាជ្ញាធរអនុវត្តច្បាប់ក្នុងតំបន់
- កាត់បន្ថយជាអប្បបរមាពីការចូលឬចេញពីបរវេណសាលារៀន
- ធានាថារាល់អ្នកមកធ្វើទស្សនកិច្ចនៅក្នុងបរវេណសាលាបានចុះឈ្មោះក្នុងការិយាល័យធំខាងមុខ
- បដិសេធមិនឲ្យរាល់បុគ្គលណាដែលមិនមានអត្តសញ្ញាណសំគាល់ខ្លួន ឬមិនមានការសំខាន់ដើម្បីចូលមកក្នុងបរិវេណសាលា
- បង្កើនការពិនិត្យក្នុងបរិវេណ ការពិនិត្យក្នុងអគារ ការពិនិត្យរាល់កញ្ចប់ដែលមិនមានម្ចាស់ ហើយរំលឹកដល់សិស្សនិងបុគ្គលិកឲ្យធ្វើការរាយការណ៍អំពីសកម្មភាពនិងករណីដែលគួរឲ្យសង្ស័យ នៅពេលដែលបានជួបប្រទះភ្លាមៗ។
- ត្រួតពិនិត្យមើលគោលការណ៍ពិធីការសំរាប់ឆ្លើយតបវិបត្តិ
- អនុវត្តការជម្លៀស និងការហ្វឹកសមសំរាប់ករណីមានជនឈ្លានពាន និងករណីបិទទ្វារមិនឲ្យចេញ ឲ្យបានពេញមួយឆ្នាំសិក្សាតែម្តង
- បើកកិច្ចពិភាក្សាអំពីអារម្មណ៍របស់សិស្សានុសិស្ស ដែលភ័យខ្លាចទាក់ទងនឹងស្ថានការណ៍ដែលមានការបាញ់កាំភ្លើងនៅសាលារៀន ហើយផ្តល់ជូនជាប្រភពធនធានជំនួយ
- ស្នើសុំឱវាទ និងសុំឲ្យមានការចុះល្បាតឆែកឆេរពីសំណាក់អជ្ញាធរអនុវត្តច្បាប់នៅក្នុងតំបន់។

បន្ថែមពីលើនេះទៀត អនុវិទ្យាល័យផ្សេងៗតែងតែធ្វើការឆែកឆេរបែបចៃដន្យជាប្រចាំ។ បើសិនជាមានមូលហេតុសមរម្យនោះ មណ្ឌលអប់រំនឹងសហការជាមួយអជ្ញាធរអនុវត្តច្បាប់ ដើម្បីធ្វើការឆែកឆេរដោយប្រើប្រាស់កងកម្លាំងឆ្កែល្បាត (K-9)។

យើងខ្ញុំបានសហការជាដៃគូជាមួយខាងអជ្ញាធរអនុវត្តច្បាប់ បង្កើតជាកម្មវិធី «ផ្លូវសុវត្ថិភាព» ដើម្បីជួយធានានូវការធ្វើដំណើរប្រកបដោយសុវត្ថិភាព ពីសាលារៀនទៅកាន់គេហដ្ឋាន។

**តើមណ្ឌលអប់រំបានធ្វើអ្វីខ្លះ ក្នុងការជួយគាំទ្រដល់ សេចក្តីត្រូវការផ្នែកប្រាស្រ័យទាក់ទងសង្គម និងផ្លូវអារម្មណ៍របស់សិស្សានុសិស្ស?**

មណ្ឌលអប់រំបានផ្តល់ជាជំនួយគាំទ្រប្រកបដោយវិជ្ជាជីវៈច្បាស់លាស់ ដល់សិស្សានុសិស្សទាំងឡាយ តាមរយៈ «ការិយាល័យផ្គត់ផ្គង់សេវាសិស្ស» (OSSS)។ ការិយាល័យ OSSS ផ្តល់ជាជំនួយដល់សិស្សានុសិស្ស ព្រមទាំងបុគ្គលិករបស់យើង ដែលបានឆ្លងកាត់ការប៉ះទង្គិចផ្លូវចិត្ត (លែងលះគ្នា ការស្លាប់របស់សមាជិកគ្រួសារ ទទួលបានការយាយី ជំងឺធ្លាក់ទឹកចិត្ត។ល។) និងបង្រៀនសិស្សអំពីជំនាញការប្រាស្រ័យទាក់ទងសង្គមផងដែរ។ មណ្ឌលអប់រំ LBUSD មានផ្តល់នូវកម្មវិធដែលរចនាឡើងដើម្បីជួយដល់សុខមាលភាពសិស្សានុសិស្សដូចតទៅ៖

- អ្នកប្រឹក្សាប្រចាំសាលា (អនុវិទ្យាល័យ និងវិទ្យាល័យ)
- វេជ្ជបណ្ឌិតចិត្តសាស្រ្តប្រចាំសាលា
- មជ្ឈមណ្ឌលសុខមាលភាព (វិទ្យាល័យ)
- មជ្ឈមណ្ឌលប្រភពធនធានគ្រួសារ (នៅបឋមសិក្សា និងអនុវិទ្យាល័យមួយចំនួន)
- ក្រុមឆ្លើយតបវិបត្តិ
- ក្រុមការងារវត្តមានសិស្សប្រចាំមណ្ឌល
- ការបង្ការនូវអំពើយាយីគ្នា

- អង្គភាពយុវជនចិញ្ចឹមបណ្តោះអាសន្ន
- ការណែនាំវិធីសាស្ត្រថែអ្នកជំងឺនៅផ្ទះ
- សេវាកម្មថែទាំសុខភាពសិស្ស
- ផែនការ 504
- ប្រព័ន្ធពហុស្រទាប់សំរាប់ការផ្តល់ជំនួយគាំទ្រ
- ការបណ្តុះបណ្តាលអំពី ការយល់ដឹងនិងការបង្ការនូវការធ្វើអត្តឃាត
- សិស្សានុសិស្សភេទទីបី និង LGBTQ+ និងប្រភពធនធាននានា

**តើមណ្ឌលអប់រំឬសាលារៀន ប្រាស្រ័យទាក់ទងជាមួយនឹងមាតាបិតានិងសហគមន៍ដូចម្តេចខ្លះ អំពីការគំរាមកំហែង ការបិទទ្វារសាលាមិនឲ្យចេញ ឬជនឈ្លានពាន ដែលអាចនឹងកើតឡើងនៅបរិវេណសាលារបស់កូនខ្ញុំឬនៅទូទាំងមណ្ឌលអប់រំ?**

មណ្ឌលអប់រំប្រើប្រាស់វិធីសាស្ត្រខុសៗគ្នាជាច្រើន ដើម្បីប្រាស្រ័យទាក់ទងទៅមាតាបិតា និងសហគមន៍។ វិធីសាស្ត្រទាំងនេះរួមបញ្ចូលទាំងការហៅទូរស័ព្ទដោយស្វ័យប្រវត្តិ (auto-dialer) ការទូរស័ព្ទមនុស្សយន្ត (robo-call) ទៅកាន់មាតាបិតាក៏ដូចជាបុគ្គលិក ហើយមានសារជាអក្សរ សំរាប់អ្នករាល់គ្នាដែលជ្រើសរើសជំរើសមួយនេះ ហើយនិងប្រព័ន្ធទំនាក់ទំនងសង្គមផ្សេងៗដូចជា Facebook Instagram និង Twitter ព្រមទាំងសារជាវីដេអូបើសិនជាចាំបាច់។

**តើខ្ញុំធ្វើដូចម្តេចទៅ បើសាលារៀនរបស់កូនខ្ញុំត្រូវបានចាក់សោបិទច្រកមិនអោយចេញបាន?**

និតិវិធីក្នុងការដោះស្រាយជាមួយមហន្តរាយធំៗ និងអ្នកឈ្លានពានលើបរិវេណសាលា រួមមានការចាក់សោបិទច្រកទ្វារមិនអោយចេញ-ចូលបាន ការជម្លៀសចេញ និងការបង្រួបបង្រួមសិស្សជុំគ្នាជាមួយមាតាបិតា/អាណាព្យាបាលរបស់ពួកគាត់វិញ គឺមានរួមបញ្ចូលនៅក្នុង «ផែនការសុវត្ថិភាពសាលាគ្រប់ជ្រុងជ្រោយ» នៅតាមសាលានីមួយៗ។ នៅក្នុងស្ថានការណ៍ដែលមានការចាក់សោបិទច្រកទ្វារមិនអោយចេញ-ចូលបាន/ការជម្លៀសចេញ គឺគេតែងតែត្រូវផ្តល់អាទិភាពទៅលើការធានាសុវត្ថិភាពរបស់សិស្សានុសិស្សជានិច្ច។ ត្រង់នេះ មានន័យថា សិស្សានុសិស្សនឹងមិនត្រូវគេអនុញ្ញាតអោយចេញទៅជួបមាតាបិតា/អាណាព្យាបាលទេ លុះត្រាតែរដ្ឋបាលខាងមន្ត្រីប៉ូលីស អគ្គិសភ័យ និងរដ្ឋបាលមណ្ឌលអប់រំកំណត់ថា ស្ថានការណ៍ដែលបណ្តាលអោយមានការចាក់សោបិទច្រកទ្វារមិនអោយចេញ-ចូលបាន/ការជម្លៀសចេញនោះ ត្រូវបានគេពិនិត្យដោះស្រាយថាល្អវិញហើយ ហើយវាមានសុវត្ថិភាពក្នុងការបង្រួបបង្រួមសិស្សានុសិស្សជុំគ្នាជាមួយមាតាបិតារបស់ពួកគាត់វិញបាន។

ក្នុងស្ថានការណ៍បែបនោះ មាតាបិតានឹងមិនត្រូវបានគេអនុញ្ញាតអោយចូលទៅក្នុងសាលាដែលទទួលផលប៉ះទង្គិចនោះឬក៏ចូលទៅយកកូនបានទេ ហើយប្រហែលជាត្រូវគេណែនាំអោយទៅកាន់កន្លែងមួយនៅឆ្ងាយពីសាលា រហូតដល់មន្ត្រីអាជ្ញាធរកំណត់ថា វាមានសុវត្ថិភាពហើយក្នុងការអនុញ្ញាតអោយសិស្សចេញបាននោះ។ នៅពេលដែលមានសុវត្ថិភាពក្នុងការធ្វើដូច្នោះបានហើយ មណ្ឌលអប់រំ និង/ឬ មន្ត្រីអាជ្ញាធរអនុវត្តច្បាប់ នឹងជូនដំណឹងដល់មាតាបិតានិងសហគមន៍ពេលណាដែលមានព័ត៌មានថ្មីៗ។ វាគឺជាការសំខាន់ណាស់ដែលមាតាបិតានិងសមាជិកសហគមន៍ ធ្វើតាមការណែនាំរបស់របស់សាលានិងអាជ្ញាធរអនុវត្តច្បាប់នៅក្នុងស្ថានការណ៍មានអាសន្ន ដើម្បីជួយធានានូវសុវត្ថិភាពនិងការទទួលខុសត្រូវលើសិស្សានុសិស្សនិងបុគ្គលិកទាំងអស់។

**តើមានភាពខុសគ្នាដូចម្តេចខ្លះ រវាងការអោយជ្រកកោណនៅនឹងមួយកន្លែង និងការចាក់សោបិទច្រកទ្វារមិនអោយចេញ-ចូលបាន?**

សកម្មភាពនៃការអោយជ្រកកោណនៅនឹងមួយកន្លែង អាចត្រូវបានគេប្រកាសដាក់ជាធរមាន ដើម្បីការពារពីគ្រោះថ្នាក់ជាយថាហេតុណាមួយដែលរួមមាន ការព្រឹលមនឹងគ្រោះថ្នាក់បរិស្ថានដូចជា ការលេចជាតិហ្គាស ឬខ្យល់មានជាតិពុលដែលចេញមកពីអាគារជិតខាងគ្នា ដោយរក្សាសិស្សានុសិស្សនិងបុគ្គលិកនៅក្នុងកន្លែងបច្ចុប្បន្នរបស់ពួកគាត់ រហូតដល់គេធានាថាវាមានសុវត្ថិភាពឡើងវិញហើយ។

ការចាក់សោបិទច្រកទ្វារមិនអោយចេញ-ចូលបាន គឺជាវិធានបន្ថែមលើសពីការជ្រកកោណនៅនឹងមួយកន្លែងទៅទៀត ដោយមានការចាក់សោ

បិទច្រកទ្វារទាំងអស់ និងការការពារមនុស្សកុំអោយចាកចេញទៅ ឬចូលមកក្នុងបរិវេណសាលាបាន។ ការចាក់សោបិទច្រកទ្វារមិនអោយចេញ-ចូលបាន អាចត្រូវបានគេប្រកាសដាក់អោយអនុវត្តភ្លាមៗ ជាវិធានការប្រុងប្រយ័ត្នមួយ ឬជាការព្រលយមចំពោះមុខនៃការគម្រាមគំហែងជាក់ស្តែងណាមួយ ដែលអាចមានមកលើសាលាឬទីតាំងណាមួយ។ ឧទាហរណ៍ ជាវិធានការប្រុងប្រយ័ត្នមួយ សាលារៀនណាមួយប្រហែលជាអាចធ្វើការចាក់សោបិទច្រកទ្វារមិនអោយចេញ-ចូលបាន នៅពេលដែលអាជ្ញាធរអនុវត្តច្បាប់កំពុងធ្វើសកម្មភាពនៅក្បែរសាលា (ទោះបីជាសកម្មភាពនោះ មិនទាក់ទងទៅនឹងសាលាដោយផ្ទាល់ក៏ដោយ) ឬនៅពេលដែលមានជនសង្ស័យឈ្លានពាន (ឬបញ្ជាក់ថាមាន) នៅលើបរិវេណសាលា។

### តើខ្ញុំធ្វើដូចម្តេច បើសាលារៀនរបស់កូនខ្ញុំ ត្រូវបានគេជម្លៀសចេញនោះ?

បើសិនជាគេកំណត់ថា ត្រូវតែជម្លៀសសិស្សានុសិស្សចេញពីសាលាដោយសារមូលហេតុសុវត្ថិភាព នោះសិស្សានុសិស្សនឹងត្រូវគេដឹកចេញទៅកាន់កន្លែងសំរាប់ការជម្លៀសទៅនោះ។ ក្នុងករណីខ្លះ ទីតាំងជម្លៀសទៅនេះ នឹងត្រូវបានកំណត់ទុកមុននៅក្នុងផែនការសុវត្ថិភាពរបស់សាលា ហើយក្នុងស្ថានការណ៍ផ្សេងៗទៀត ទីតាំងសំរាប់ការជម្លៀសទៅនោះប្រហែលជាត្រូវបានគេកំណត់ដោយមានកិច្ចសហការគ្នាជាមួយអាជ្ញាធរអនុវត្តច្បាប់ អាស្រ័យទៅតាមសេចក្តីត្រូវការខាងសុវត្ថិភាពនិងសន្តិសុខ។

ក្នុងស្ថានការណ៍ដូច្នោះ មាតាបិតាទាំងឡាយនឹងមិនត្រូវបានគេអនុញ្ញាតអោយចូលទៅក្នុងសាលាដែលទទួលផលប៉ះទង្គិចនោះ ឬចូលទៅយកកូនរបស់ពួកគាត់បានទេ លុះត្រាតែវាមានសុវត្ថិភាពធ្វើដូច្នោះបាន ហើយសិស្សានុសិស្សទាំងអស់ត្រូវបានគេរាប់ថាមានវត្តមានគ្រប់ចំនួនសិន។ មាតាបិតា ប្រហែលជាត្រូវបានគេណែនាំអោយទៅកាន់ទីតាំងមួយដែលនៅឆ្ងាយពីសាលា រហូតដល់អាជ្ញាធរមានសមត្ថកិច្ចកំណត់ថា វាមានសុវត្ថិភាពក្នុងការអោយសិស្សចេញបានសិន។ នៅពេលដែលមានសុវត្ថិភាពអាចធ្វើដូច្នោះបាន មណ្ឌលអប់រំ និង/ឬ មន្ត្រីអាជ្ញាធរអនុវត្តច្បាប់នឹងធ្វើការទំនាក់ទំនងទៅកាន់មាតាបិតា និងសមាជិកសហគមន៍ ពេលណាដែលពួកគេមានព័ត៌មានថ្មីៗ។ វាគឺជាការសំខាន់ណាស់ដែលមាតាបិតានិងសមាជិកសហគមន៍ ធ្វើតាមការណែនាំរបស់សាលានិងអាជ្ញាធរអនុវត្តច្បាប់ ក្នុងស្ថានការណ៍មានអាសន្ន ដើម្បីធានានូវសុវត្ថិភាពរបស់សិស្សានុសិស្សនិងបុគ្គលិកបាន។

### តើខ្ញុំទៅយកកូននៅកន្លែងណាទៅ បើសិនជាសាលារបស់ពួកគាត់ត្រូវបានគេជម្លៀសចេញនោះ?

ក្រោយពីឧប្បត្តិហេតុនោះត្រូវបានគេអោយសញ្ញាថា "គ្រប់យ៉ាងគឺល្អវិញហើយ"
នោះមណ្ឌលអប់រំនឹងជូនដំណឹងទៅកាន់មាតាបិតាដោយការ ហៅតាមទូរសព្ទ សារជាអក្សរប្រកាសលើព័ន្ធផ្សព្វផ្សាយសង្គម
និងសារជាអក្សរផ្ញើរតាមទូរសព្ទ ដោយមានព័ត៌មានអំពីការបង្រួបបង្រួមជួបជុំគ្នា ជាមួយកូនវិញ
ដែលរួមទាំងកន្លែងនិងវិធីទៅយកកូនរបស់ពួកគាត់ផងដែរ។ ព័ត៌មាននេះ ប្រហែលជាអាចជាទីតាំងដូចគ្នានឹងកន្លែងជម្លៀស
សិស្សានុសិស្សទៅនោះដែរ ឬក៏សិស្សានុស្សប្រហែលជាអាចត្រូវគេដឹកទៅដាក់នៅទីតាំងពិសេសណាមួយសំរាប់បង្រួបបង្រួមជួបជុំគ្នាវិញ។

### តើមណ្ឌលអប់រំមានជួលបុគ្គលិកផ្នែកសុវត្ថិភាពដែរឬទេ?

មណ្ឌលអប់រំ LBUSD មានការិយាល័យសុវត្ថិភាពសាលានិងការត្រៀមលក្ខណៈសំរាប់សង្គ្រោះបន្ទាន់ (Office of School Safety and Emergency Preparedness) ដែលក្រុមប្រឹក្សាភិបាលអប់រំប្រគល់តួនាទីអោយទទួលខុសត្រូវក្នុងការទ្រទ្រង់បរិស្ថានប្រកបដោយសុវត្ថិភាពនិងសន្តិសុខ សំរាប់សិស្សានុសិស្ស បុគ្គលិកសិក្សា និងបុគ្គលិកទាំងអស់ នៅក្នុងមណ្ឌលអប់រំឡុងប៊ីចទាំងមូល។

ក្រោមដឹកនាំរបស់ប្រធានការិយាល័យសុវត្ថិភាពសាលានិងការត្រៀមលក្ខណៈសំរាប់សង្គ្រោះបន្ទាន់ (Office of School Safety and Emergency Preparedness) ការិយាល័យសុវត្ថិភាពសាសានេះ ផ្តល់សេវាកម្មទៅកាន់សាលារៀននានា រយៈពេល24ម៉ោងក្នុងមួយថ្ងៃ និង7ថ្ងៃក្នុងមួយសប្តាហ៍។ បុគ្គលិករបស់ការិយាល័យនេះ មានវត្តមានឆ្លើយតបចំពោះ ការហៅទូរសព្ទសុំសេវាកម្មជាច្រើនប្រភេទ មានទាំងការរក្សាសណ្តាប់ធ្នាប់និងវិន័យ ការស្វែងរកសិស្សដែលបាត់ខ្លួន ការស៊ើបអង្កេតលើការរំលោភបំពានលើគោលការណ៍ច្បាប់របស់ក្រុមប្រឹក្សាភិបាល

សាលារៀន ការឃាត់ខ្លួនសិស្សដែលរំលោភបំពានច្បាប់ឬគោលការណ៍ច្បាប់របស់ក្រុមប្រឹក្សាភិបាលសាលារៀនស្តីអំពីទ្រព្យសម្បត្តិរបស់សាលា និងព្រឹត្តិការណ៍ផ្សេងៗដែលឧបត្ថម្ភដោយសាលា ព្រមទាំងឆ្លើយតបចំពោះការសង្គ្រោះបន្ទាន់ទាំងឡាយ។

ក្នុងពេលមានសង្គ្រោះបន្ទាន់ណាមួយ ការិយាល័យសុវត្ថិភាពសាលានិងការត្រៀមលក្ខណៈសំរាប់សង្គ្រោះបន្ទាន់ (Office of School Safety and Emergency Preparedness) អាចប្រកាសដាក់ មជ្ឈមណ្ឌលប្រតិបត្តិការសង្គ្រោះបន្ទាន់ Emergency Operations Center (EOC) ទាំង6 ក្នុងប្រតិបត្តិការសកម្មទៅតាមកំរិតអាសន្នត្រឹមត្រូវសមរម្យ ដើម្បីសំរបសំរួលក្នុងការឆ្លើយតបចំពោះការសង្គ្រោះបន្ទាន់ទាំងឡាយរបស់មណ្ឌលអប់រំ។ ក្នុងពេលទទួលបានសេចក្តីប្រកាសជូនដំណឹងភ្លាមៗ ការិយាល័យនេះនឹងដាក់បុគ្គលិកEOC អោយតាមដានឃ្លាំមើលស្ថានការណ៍ និងកំណត់នូវក្រសួងពាក់ព័ន្ធនិងធនធានទាំងឡាយដែលត្រូវការចាំបាច់ ដើម្បីបំពេញតួនាទីដ៏សំខាន់ៗទាំងនេះ។ អ្នកធ្វើសេចក្តីសំរេច និងតំណាងសំខាន់ៗមកពីការិយាល័យផ្សេងៗរបស់មណ្ឌលអប់រំ នឹងរាយការណ៍ទៅកាន់ការិយាល័យ EOC និងធ្វើការរួមគ្នាដើម្បីស្តារឡើងវិញនូវបរិស្ថានប្រកបដោយសុវត្ថិភាពនិងសន្តិសុខសំរាប់សិស្សានុសិស្សនិងសាលារៀនទាំងឡាយរបស់យើង។ នៅតាមសាលាវិទ្យាល័យ ក្នុងមណ្ឌលអប់រំ LBUSD មន្ត្រីទទួលបន្ទុកផ្នែកសុវត្ថិភាព ធ្វើការល្បាតនិងឃ្លាំមើលបរិវេណជុំវិញសាលារៀន ហើយអាចឆ្លើយតបភ្លាមៗទៅកាន់សាលារៀនទាំងឡាយនៅពេលដែលចាំបាច់។ សាលាអនុវិទ្យាល័យ MS និង K-8 មានជំនួយការបុគ្គលិកដែលគ្មានបំពាក់ដោយអាវុធនៅតាមបរិវេណសាលា ដែលពួកគាត់មានមុខងារផ្តល់សន្តិសុខបន្ថែមនិងការប្រាស្រ័យទំនាក់ទំនងតាមវិទ្យុទាក់ទង។ អ្នកធ្វើការស្ម័គ្រចិត្ត និងមន្ត្រីសុវត្ថិភាពសាលា ជួយការងារសុវត្ថិភាពដល់សាលាទាំងអស់ រួមទាំងសាលាបឋមសិក្សារបស់យើងផងដែរ។

**តើការឆ្លើយតបក្នុងការសង្គ្រោះបន្ទាន់មានប៉ុន្មានកំរិត?**

LBUSD ប្រើគំរូរបស់ ប្រព័ន្ធគ្រប់គ្រងការសង្គ្រោះបន្ទាន់ថ្នាក់ជាតិ-National Emergency Management System (NEMS) ដែលផ្តល់ការណែនាំដល់ស្ថាប័នរដ្ឋាភិបាលគ្រប់កំរិតទាំងអស់ អង្គការក្រៅរដ្ឋាភិបាល (NGOs) និងស្ថាប័នឯកជន ដើម្បីធ្វើការរួមគ្នាក្នុងការបង្ការ ការពារតទល់ សំរួលបន្ធូរបន្ថយ ឆ្លើយតប និងងើបចេញពីឧប្បត្តិហេតុទាំងឡាយឡើងវិញ។ នៅក្រោមប្រព័ន្ធនេះ កំរិតផ្សេងៗគឺមានសំរាប់ប្រកាស់ដាក់ប្រតិបត្តិការសកម្មរបស់មជ្ឈមណ្ឌលប្រតិបត្តិការសង្គ្រោះបន្ទាន់របស់LBUSD ឬហៅកាត់ថា EOC។

កំរិតទាំងនេះរួមមាន៖

- កំរិតទី3៖ មជ្ឈមណ្ឌល EOC មិនទាន់ត្រូវបានគេប្រកាស់ដាក់ក្នុងប្រតិបត្តការសកម្មនៅឡើយទេ ប៉ុន្តែគេកំពុងតាមដានឃ្លាំមើលស្ថាភាព។
- កំរិតទី2៖ បុគ្គលិកទទួលបន្ទុកលើសុវត្ថិភាពសាលា មានវត្តមាននៅកន្លែង EOC។
- កំរិតទី1៖ ក្រុមការងារ LBUSD ទាំងមូល ត្រូវបានប្រកាសដាក់ក្នុងប្រតិបត្តិការសកម្ម ឧទាហរណ៍ នៅក្នុងកំឡុងពេលមានការរញ្ជួយផែនធ្ងន់ធ្ងជាដើម។